# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅស្វាយប៉ាក
# ថ្ងៃទី១៦ កក្កដា ២០១៧

| |
|---|
| អត្ថបទទី១៖អស ៥៥,១០-១១ |
| អត្ថបទទី២៖រម ៨,១៨-២៣ |
| ដំណឹងល្អ៖មថ ១៣,១-២៣ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពសន្តីម៉ារីម៉ាដាឡា ដែលជាឧបការីសម្រាប់ព្រះសហគមន៍នៅស្វាយប៉ាកនេះ។ ជាឱកាសមួយ ដើម្បីនឹកឃើញដល់ជីវិតរបស់សន្តីម៉ារីម៉ាដាឡា នៅក្នុងគម្ពីរយើងបានស្តាប់ថា **ពេលនាងកំពុងតែនិយាយដូច្នេះ នាងមើលទៅក្រោយឃើញព្រះយេស៊ូនៅទីនោះ តែនាងមើលព្រហអង្គមិនស្គាល់ទេ** នៅពេលនោះព្រះយេស៊ូសោយទិវង្គត់នាងម៉ារីម៉ាដាឡាទៅមើលផ្នូររបស់ព្រះយេស៊ូដើញមានផ្នូរទទេ មានទេវទូតដែលកំពុងតែនិយាយជាមួយគាត់ និងព្រះយេស៊ូយាងមក។ នាងម៉ារីម៉ាដាឡា បានធ្វើដំណើរជាមួយព្រះយេស៊ូប្រហែល៣ឆ្នាំ ប៉ុន្តែពេលព្រះយេស៊ូបង្ហាញខ្លួនឲ្យគាត់ឃើញម៉ារីម៉ាដាឡាមើលមិនស្គាល់ព្រះយេស៊ូទេ។ ព្រះយេស៊ូសួរគាត់ថា **នាងអើយម្តេចក៏នាងយំ នាងរកអ្នកណា?** តែគាត់មើលមិនស្គាល់ជាព្រះយេស៊ូទេ។ ប៉ុន្តែពេលព្រះយេស៊ូហៅនាងថា **ម៉ារី** គាត់ភ្ញាក់ហើយទទួលស្គាល់ថានេះជាព្រះយេស៊ូ តាមរយៈរបៀបដែលព្រះយេស៊ូហៅគាត់ ណែនាំឲ្យគាត់យល់ភ្លាមថា នេះជាព្រះយេស៊ូដែលកំពុងនិយាយជាមួយខ្ញុំ។ គាត់បានធ្វើដំណើរជាមួយព្រះយេស៊ូ ដូច្នេះប្រហែលព្រះយេស៊ូមានរបៀបមួយពិសេសនៅពេលព្រះយេស៊ូហៅគាត់ថា **ម៉ារី** ពេលគាត់លឺគាត់ដឹងច្បាស់ថាជាព្រះយេស៊ូដែលកំពុងហៅគាត់ពិតម៉ែន។

ទំនាក់ទំនងដែលនាងម៉ារីម៉ាដាឡា បានបង្កើតជាមួយព្រះយេស៊ូជាទំនាក់ទំនងមួយយ៉ាងពិសេស និងជិតស្និតជាមួយព្រះយេស៊ូ រហូតដល់ពេលព្រះយេស៊ូត្រូវគេឆ្កាងមានតែនាងម៉ារីម៉ាដាឡា លោកយ៉ូហាន និងព្រះនាងម៉ារីដែលនៅក្បែរឈើឆ្កាង។ នាងម៉ារីម៉ាដាឡាបានស្រឡាញ់ព្រះយេស៊ូ ហើយព្រះយេស៊ូក៏បានស្រឡាញ់គាត់ ណឹងណែនាំឲ្យនាងម៉ារីម៉ាដាឡាក្លាយជាសាវ័កទីមួយ ដែលធ្វើសាក្សីអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នឹងជាសាវ័កទីមួយដែលទៅប្រកាសថា ពិតម៉ែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ។ ពេលយើងឃើញជីវិតរបស់នាងម៉ារីម៉ាដាឡា យើងត្រូវការនឹកដល់ព្រះសហគមន៍របស់យើងសព្វថ្ងៃដែលបានធ្វើដំណើរជាមួយព្រះយេស៊ូ ដោយទទួលតួនាទីមួយ គឺធ្វើជាសាក្សី

អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ **តើយើងធ្វើដូចម្តេច ដើម្បីផ្តល់សក្ខីភាពអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ?** នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលជាប់ជាមួយព្រះយេស៊ូ យើងធ្វើដូចម្តេចដើម្បីបង្ហាញអំពីជីវិតដែលព្រះយេស៊ូប្រទានឲ្យយើង។ យើងត្រូវការយកសក្ខីភាពជាចំបង តើយើងត្រូវការបំពាក់អ្វីខ្លះដើម្បីផ្តល់សក្ខីភាព?

ទីមួយ យើងត្រូវការបំពាក់ព្រះយេស៊ូ មានន័យថាយើងត្រូវការជិតស្និតជាមួយព្រះយេស៊ូ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានទទួលអាវសដែលជាសញ្ញាបញ្ជាក់ថា ចាប់ពីពេលនេះតទៅយើងបំពាក់ព្រះយេស៊ូ។

ទីពីរ ឲ្យយើងភ្ជាប់ជាមួយព្រះបន្ទូលរបស់ព្រះយេស៊ូ ឲ្យយើងអានព្រះបន្ទូល ស្តាប់ព្រះបន្ទូលជារៀងរាល់ថ្ងៃ។

ទីបី អធិដ្ឋាន មុនផ្តល់សក្ខីភាពយើងត្រូវការអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃ ទោះបីយើងមិនចូលព្រះវិហារយើងដឹងថា ដួងចិត្តរបស់យើងជាព្រះវិហារតូចមួយ យើងធ្វើដូចម្តេចដើម្បីចូលនៅក្នុងព្រះវិហារនេះ? រាល់ថ្ងៃយើងអាចចូលនៅក្នុងព្រះវិហារតូចរបស់យើងដើម្បីអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់សម្រាប់ក្រុមគ្រួសារយើង សម្រាប់ព្រះសហគមន៍ សម្រាប់បងប្អូនឯទៀតៗ សម្រាប់សង្គមយើង សម្រាប់សុខសន្តិភាពនៅក្នុងពិភពលោក។

ទីបួន ថែរក្សាសេចក្តីស្រឡាញ់ជានិច្ច តើយើងបានផ្តល់សេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗឬទេ? យើងបានស្រឡាញ់អ្នកដទៃ យើងបានបង្កើតទំនាក់ទំនងល្អនៅក្នុងភូមិដោយថែរក្សាសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់។

ទីប្រាំ លើកលែងទោស ប្រសិនបើយើងមិនចេះលើកលែងទោស យើងអន់ចិត្តគ្នាក្រោយមកយើងចោលព្រះវិហារដោយសារយើងមានបញ្ហាជាមួយគេ។ គ្រីស្តបរិស័ទជាអ្នកដែលចេះលើកលែងទោសជានិច្ច។

ទីប្រាំមួយ ឲ្យយើងមានសេចក្តីក្លាហានដើម្បីប្រកាសដំណឹងល្អ ដើម្បីរស់នៅតាមព្រះបន្ទូលរបស់ព្រះយេស៊ូតែម្តង ដើម្បីបង្ហាញអំពីជំនឿរបស់យើងដល់បងប្អូនឯទៀតៗ។ ដោយធ្វើជាគ្រីស្តបរិស័ទសកម្ម ដូចក្នុងអត្ថបទទីពីរ **ព្រះហឫទ័យរបស់ព្រះគ្រីស្តជម្រុ**

**ញយើង** គ្រីស្តបរិស័ទសកម្មគឺមិនភ័យខ្លាច ប៉ុន្តែគ្រប់ពេលវេលាទុកឲ្យព្រះហឫទ័យរបស់ព្រះគ្រីស្តជម្រុញយើង។ នៅពេលនោះពិតម៉ែន យើងអាចយកសក្ខីភាពជាចំបងដូចនាងម៉ារីម៉ាដាឡា ដែលនាងជាសាក្សីមុនគេបង្អស់ ដើម្បីឲ្យគ្រីស្តទូតស្តាប់ដំណឹងល្អមួយយ៉ាងពិសេស គឺព្រះយេស៊ូមានព្រះជន្មរស់ឡើងម៉ែន។ យើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែលពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

ពេលខ្ញុំដើរតាមផ្ទះបងប្អូនគ្រីស្តបរិស័ទនៅសន្តប៉ូល គេជាគ្រីស្តបរិស័ទដំបូង ហើយគេបានយកចិត្តទុកដាក់ប្រកាសដំណឹងល្អម៉ែនទែន។ ពេលខ្ញុំទៅដល់ផ្ទះគេ ភាគច្រើនជាអ្នកក្រីក្រ ប៉ុន្តែពេលនោះមានប្រជាជនមកច្រើន ដើម្បីស្តាប់គ្រីស្តបរិស័ទយើងផ្តល់សក្ខីភាព។ ដូច្នេះបងប្អូនសូមមានសេចក្តីក្លាហានជានិច្ច សេចក្តីក្លាហានមកពីព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះវិញ្ញាណដ៏វិសុទ្ធជម្រុញយើង ឲ្យយើងចេញដើម្បីបន្តប្រកាសដំណឹងល្អ។

យើងអរព្រះគុណព្រះជាម្ចាស់ តាមរយៈសន្តីម៉ារីម៉ាដាឡា យើងទូលអង្វរព្រះអង្គដើម្បីឲ្យយើងទៅជាគ្រីស្តបរិស័ទ ដែលយកសក្ខីភាពជាចំបងជានិច្ច។ អាម៉ែន៕